សាកល្បងពិចារណាលើ ៖

# ការវិវត្តបែបថយក្រោយ ?

នៅក្នុងពិភពលោកនេះ គេសង្កេតឃើញថាមាន ការវិវត្ត នៃនយោបាយច្រើនដំណាក់ការ ឆ្ពោះទៅរកលទ្ធិប្រជាធិបតេយ្យ : នៅទស្សវត្ស២០ វាមានចាប់មានពន្លក នៅក្នុងមជ្ឈដ្ឋាននយោបាយ នៃអ្នកយុវប្រជាធិបតេយ្យនិយម ; តែនៅក្នុងទស្សវត្ស៣០ របបផ្តាច់ការ នៅមានឥទ្ធិពលខ្លាំងក្លានៅឡើយ ; មកដល់ទស្សវត្ស៤០ ចាប់ផ្តើមមានរស្មី នៃអ្នកជាតិនិយម ដែលនាំធ្វើអោយរីកសាយ នៃពួកអ្នកប្រឆាំងនឹងអាណានិគមនិយម នៅទស្សវត្ស៥០ និង ៦០ ; នៅទស្សវត្ស៧០ ជាជំនាន់ នៃ ជាមេដឹកនាំចាស់ទុំ ; មកដល់ទស្សវត្ស៨០ និង ៩០ មានផុសជាថ្មី នៃអ្នកយុវប្រជាធិបតេយ្យនិយម ឡើងកាន់អំណាច យកលទ្ធិប្រជាធិបតេយ្យសេរី ជាមូលដ្ឋាន នៃការដឹកនាំ, តែនាបច្ចុប្បន្ននេះ គេឃើញថាមាន ការវិវត្តបែបថយក្រោយ ឆ្ពោះទៅរកអំណាចផ្តាច់ការវិញ។ ការវិវត្តបែបនេះ មានអ្នកដឹកនាំមួយចំនួន នៅលើពិភពលោក ជាអទិករ ដូចយ៉ាងលោក Vladimir Putin នៅប្រទេសរុស្ស៊ី, Xi Jinping នៅប្រទេសចិនកុម្មុយនិស្ត, Recep Tayyip Erdogan នៅប្រទេសតួកគី, Rodrio Durterte នៅប្រទេសហ្វីលីពីន និង លោក Viktor Orban នៅប្រទេសហុងគ្រី។ មេដឹកនាំទាំងនោះ សុទ្ធតែមានគោលលទ្ធិ សំរាប់យកមកធ្វើជាមូលដ្ឋាននយោបាយរបស់ខ្លួនរៀងៗខ្លួន ដូចយ៉ាង :

លោក Vladimir Putin : ដើម្បីស្តារឡើងវិញ នូវភាពអស្ចារ្យ នៃចក្រភពរុស្ស៊ី នយ:ជន[1]នេះ យកមូលដ្ឋានបីយ៉ាង ជាគ្រឹះ នៃគោលលទ្ធិរបស់គាត់ គឺ : គន្លប្បជិបទា[2], អត្តាធិបតេយ្យ និង ជាតិនិយម។ មូលដ្ឋានទាំងនេះ ត្រូវការមាន មេដឹកនាំផ្តាច់ការមួយ ដែលគាត់មានជំនឿថា រូបគាត់នេះឯង ជាអវតា។

លោក Xi Jinping : នយ:ជននេះ យល់ឃើញថា គណបក្សកុម្មុយនិស្តចិន កំពុងជួបប្រទះនឹងគ្រោះថ្នាក់ ដូច្នេះ ត្រូវចាំបាច់ស្តារឡើងវិញ នូវអំណាចរបស់គណបក្ស ដោយពង្រឹងអំណាចរបស់គាត់ ដែលជាមេដឹកនាំ រដ្ឋ និង បក្ស។ ក្នុងជំហរនេះ ដែលនាំអោយគាត់ធ្វើវិសោធនកម្មច្បាប់ នៃការដឹកនាំមួយចំនួន ជាពិសេសគឺ លុបចោលអាណត្តិដោយមានកំណត់ពេលវេលា នៃអ្នកដឹកនាំកំពូល នៃប្រជាជាតិ និង បក្ស ក្នុងគោលបំណងធ្វើអោយមានស្ថេរភាពនយោបាយ។

លោក Recep Tayyip Erdogan : នយ:ជននេះ យល់ឃើញថា ដើម្បី មោទនភាព នៃសាសនាអ៊ីស្លាម ត្រូវចាំបាច់ យកប្រជានិយមផ្តាច់ការ ជាមូលដ្ឋាននយោបាយ។ បការនេះ លោក Ataturk[3] ជាបិតាជាតិតួកគី ធ្លាប់យកមកអនុវត្តប្រកបដោយ

---

1 នត:ជន= អ្នកនយោបាយ ឬ អ្នកដឹកនាំនយោបាយ។
2 គន្លប្បជិបទា = ត្រូវតាមច្បាប់សាសនា (Orthodoxie)។
3 លោក Kemal Atatürk កើតនៅថ្ងៃទី១៩ ឧសភា ឆ្នាំ ១៨៨១ ទទួលមរណភាពនៅថ្ងៃទី១០ វិច្ឆិកា ឆ្នាំ ១៩៣៨។ លោក ជា រដ្ឋបុរស នៃប្រជាជាតិតួកគី ហើយជា ស្ថាបនិក និង ប្រធានាធិបតីទី១ នៃសាធារណរដ្ឋ តួកគី (១៩២៣-១៩៣៨)។

ជោគជ័យ ដើម្បី ការរីកចំរើន និង នគរូបនីយកម្ម នៃប្រជាជាតិតួកគី។

លោក Rodrio Durterte : នយៈជននេះ យកគំរូ នៃប្រទេសសិង្ហបុរី មកធ្វើជាគោលវិធីរដ្ឋាភិបាល ដើម្បីប្រឆាំងនឹង អំពើឧក្រិដ្ឋកម្មនៅក្នុងសង្គម។ គោលនយោបាយនោះ គឺឈរលើគោលវិធី នៃបច្ចេកទេសនិយម ជារបៀបដឹកនាំ។

លោក Viktor Orban : នយៈជននេះ យល់ឃើញថា ប្រជានិយមជាតិនិយម វាជាចម្លើយមួយ ដើម្បីរក្សាអំណាចរបស់គាត់ និងបក្សកាន់អំណាច ក្នុងគោលដៅការពារប្រយោជន៍ នៃប្រទេសហុងគ្រី នៅក្នុងសហគមអឺរ៉ុប និង នៅលើពិភពលោក។

គោលគំនិតខាងលើនេះ សុទ្ធតែជាគំនិតប្រឆាំងនឹងលទ្ធិប្រជាធិបតេយ្យសេរី ដែលពួកគាត់ យល់ឃើញថា ជាលទ្ធិមួយ វាមិនឆ្លើយតបនឹងភាពជាក់លាក់ នៃប្រទេស និង ប្រជាជននីមួយៗទេ។ ជាការពិត គោលជំហរនេះ អាចលើកយកមកធ្វើជាការសំអាងបាន ដោយសារប្រទេសធំៗ ដែលអនុវត្ត លទ្ធិប្រជាធិបតេយ្យសេរី កំពុងជួបប្រទះវិបត្តិ រចនាសម្ព័ន្ធ និងសេដ្ឋកិច្ច ដែលធ្វើឱ្យ ការជំរុញលទ្ធិប្រជាធិបតេយ្យ នៅលើពិភពលោកធ្លាក់ចុះបន្តិច។ តែត្រូវចងចាំជានិច្ចថា នៅទសវត្សរ៍៩០ ការដួលរលំ នៃសហភាពសូវៀត វាបង្ហាញពីជ័យជំនះយ៉ាងច្បាស់ នៃលទ្ធិប្រជាធិបតេយ្យសេរី លើលោកកុម្មុយនិស្ត។ ជ័យជំនះនេះ អនុញ្ញាតឱ្យប្រទេសនៅភាគខាងកើតនៅអឺរ៉ុប

ជាច្រើនផ្តាច់ខ្លួនចេញពី លទ្ធិកុម្មុយនិស្ត ហើយជ្រើសរើសយក លទ្ធិប្រជាធិតេយ្យសេរី ជាវិធី នៃការដឹកនាំជាតិ។ បច្ចុប្បន្ននេះ ទោះបីលទ្ធិប្រជាធិបតេយ្យ ជួបប្រទះការលំបាកមួយចំនួនជាពិសេសនៅចំពោះមុខ ការងើបឡើង នៃគំនិតជាតិនិយម តែមិនទាន់មាន ប្រទេសខាងកើត នៅអឺរ៉ុបណាមួយ បានបោះបង់លទ្ធិប្រជាធិបតេយ្យសេរី នៅឡើយទេ រួមទាំងប្រទេសហុងគ្រី ព្រោះ លទ្ធិប្រជាធិបតេយ្យសេរី អនុញ្ញាតឱ្យមានជម្រើសនយោបាយដឹកនាំ នៅក្នុង សន្តិភាព និង ស្ថេរភាព វាផ្ទុយពីការអះអាងរបស់ក្រុមអ្នករិះគន់។ ត្រូវដឹកថា លទ្ធភាពនេះ អាចមានបាន ដោយសារ វាគ្មានតក្ក នៃសត្រូវនយោបាយដាច់ខាត ព្រោះជា លទ្ធិអនុញ្ញាតពហុបក្ស នៅក្នុងការបោះឆ្នោតដោយសេរី និង យុត្តិធម៌ ដើម្បីជ្រើសរើសអ្នកដឹកនាំ។

ពិតប្រាកដណាស់ថា លោកខាងលិច ឬ មស្ជឹមប្រទេស មានការយល់ច្រឡំ ដោយចាត់ទុកខ្លួនឯង ជាមជ្ឈឹមលោក ជាជាងទទួលស្គាល់ថាខ្លួនឯង គ្រាន់តែជា វត្ថុធាតុមួយតែប៉ុណ្ណោះ នៅក្នុងពិភពលោកដ៏ស្មុគស្មាញ។ ការយល់ច្រឡំនេះ នាំឲខ្លួន ទុកវប្បធម៌របស់ខ្លួន ជាសញ្ញាល័ក្ខ នៃទំនើបភាវូបនីយកម្ម ដែលវានឹងអាចប៉ះទង្គិច ចំពោះវប្បធម៌ផ្សេងទៀត ដែលទុកប្រពៃណីជាតម្លៃ នៃនិមិត្តរូបជាតិ ហើយយក អត្តសញ្ញាណប្រពៃណី ជាភាសា នៃការតស៊ូប្រឆាំងទៅនឹង ការធ្វើទំនើបកម្ម សង្គមសេដ្ឋកិច្ច និង នយោបាយ ទៅនឹងគំរូលោកខាងលិច ដូចយ៉ាង មនោគមវិជ្ជាអ៊ីស្លាមថ្មីសព្វថ្ងៃ ដែលបង្កើតជាចលនា

បដិវត្ត ជាក្រុមផ្សេងៗគ្នា ហើយ ធ្វើការតស៊ូប្រយុទ្ធគ្នា យកអំណាចនៅតំបន់ ដែលមានប្រជាជនម៉ូស្លីមភាគច្រើន។ ការប្រយុទ្ធនេះបង្កើត នូវសកម្មភាពភេរវកម្ម នៅក្នុងប្រទេសលោកខាងលិច រួមទាំង សហរដ្ឋអាមេរិក ដែលធ្វើអន្តរាគមន៍នៅក្នុងតំបន់ទាំងនេះ។ ក្នុងស្ថានភាពច្របូកច្របល់នេះ ផ្តល់នូវរូបភាព នៃការធ្លាក់ចុះ នៃលទ្ធិប្រជាធិបតេយ្យសេរី។ តែទោះបីយ៉ាងណា លទ្ធិប្រជាធិបតេយ្យសេរី នៅមានរស្មីជានិច្ចព្រោះវាជាចលករចម នៃវឌ្ឍនភាព ដែលបញ្ជាក់ នូវតម្លៃជាវិជ្ជមានរួចហើយ។ អំណាច នៃការសាយ និង ការទាញ របស់លទ្ធិនេះ វាកាន់តែខ្លាំងឡើង ហើយ វាបង្កើតបានជាឆន្ទៈ និង ការភ្នាល់ នៅចំពោះមុខពួកដែលមិនជឿ ដោយសារតែខ្លួនមានប្រយោជន៍ក្រុម និង បុគ្គល សំរាប់ការពារ ដែលជាប្រយោជន៍ផ្ទុយនឹងប្រយោជន៍រួម និង សាកល។ លទ្ធិប្រជាធិបតេយ្យសេរីមាន បទពិសោធន៍ ប្រកបដោយជោគជ័យ ផ្តល់ជូន សំរាប់អ្នកប្រជាធិបតេយ្យនិយម ជំនាន់បន្តៗមក យកមកអនុវត្តដោយបញ្ញាថ្មី សំរាប់សម្របខ្លួនទៅនឹងបរិបទថ្មី, ប៉ុន្តែ ការបោះបង់ចោល នូវមូលដ្ឋានគ្រឹះ នៃលទ្ធិ គឺជាកំហុសមួយ ហើយនៅពេលឆាប់ ឬ យូរ តែប៉ុណ្ណោះ នឹងនាំមក នូវគ្រោះមហន្តរាយជាពុំខាន ព្រោះមូលដ្ឋានគ្រឹះនេះឯង ដែលផ្តល់ នូវការពេញចិត្តគ្រប់គ្រាន់ ដើម្បីជានាដល់ សន្តិភាព និង ការអភិវឌ្ឍប្រកបដោយចីរភាព។ ការសំគាល់ឃើញថា ការវិវត្តបែបថយក្រោយ នៃលទ្ធិប្រជាធិបតេយ្យ វាជាការសង្កេតជាអត្តវិស័យ តែត្រូវដឹងថា លទ្ធិប្រជាធិបតេយ្យសេរី វិវត្តមកដល់សព្វថ្ងៃ មាន វិ

មាត្រ និង កម្រាស់ មាំទាំ ជា ប្រព័ន្ធ និង ជាស្ថាប័ន នៃសន្តិភាព សំរាប់ការពារខ្លួនឯងបាន នៅចំពោះមុខ គោលចំណង់នៃលោក Vladimir Putin ជាមហាបុរស នៃរបបនៅប្រទេសរុស្ស៊ី, Xi Jinping ជាវិរបុរសថ្មី នៃបក្សកុម្មុយនិស្តចិន, Recep Tayyip Erdogan ជាមាគ៌ា នៃសាសនាអ៊ីស្លាម នៅប្រទេសតួកគី, Rodrio Durterte ជាមេដឹកនាំ បច្ចេកទេសនិយម នៅប្រទេសហ្វីលីពីន និង លោក Viktor Orban ជាអ្នកប្រជានិយមជាតិនិយម នៅប្រទេសហុងគ្រី ដែលពួកគាត់ បង្ហាញ ភាពទន់ខ្សោយ ឬ បរាជ័យ នៃលទ្ធិប្រជាធិបតេយ្យសេរី វាគ្រាន់តែការធ្វើវិរកម្មតាមទំលាប់ ដែលខ្លួនធ្លាប់ស្គាល់ ដើម្បី ការពារប្រយោជន៏ផ្ទាល់ខ្លួន ឬ របបដឹកនាំតែប៉ុណ្ណោះ តែវាគ្មានអត្ថរស់ទំនើប សំរាប់អាចយកឈ្នះលទ្ធិប្រជាធិបតេយ្យសេរីបាននោះឡើយ។ ទម្លាប់ដែលលោក ពូទីន និង ជីនពីង ស្គាល់គឺលទ្ធិកុម្មុយនិស្ត ដែលធ្លាប់បង្ហាញ អំពើឃោឃៅ ឬ អមនុស្សធម៌ នាសតវត្សទី២០ រួចមកហើយ។ ចំណែកលោក ដួរតែតវិញ គាត់បានយកគំរូលោក ម៉ាកូស ជាខ្សែនាយក នៃនយោបាយរបស់គាត់ ដោយបន្ថែម នូវខ្នាត នៃបច្ចេកទេសនិយម។ រីឯលោក អែដូង៉ាន់ និង អោបង់ វិញ គាត់យកទម្លាប់ចាស់ គឺជាតិនិយមនៅទស្សវត្ស៥០ មកធ្វើជាឧបករណ៍នយោបាយ សំរាប់បញ្ឆោតប្រជាជននៅក្នុងប្រទេសរបស់គាត់រៀងៗខ្លួន។ ប៉ុន្តែការពិត ការធ្វើវិរកម្មតាមទំលាប់នេះ មានគោលដៅតែមួយគត់ គឺ ពង្រឹងអំណាចបក្ស និង ផ្ទាល់ខ្លួន តែ

ប៉ុណ្ណោះ។ គំរូនេះ វាទាក់ទាញ និង លើកទឹកចិត្ត ដល់ជនផ្តាច់ការមួយចំនួននៅលើពិភពលោក។ ពួកនរៈនោះ យកគំរូនេះ សំរាប់បង្ហាញអំពីភាពត្រឹមត្រូវ នៃសកម្មភាពទុច្ចរិតរបស់ពួកគេ ដោយប្រើខែល នៃអធិបតេយ្យភាព ជាអាវុធ ដើម្បីការពារប្រឆាំងនឹង ការរិះគន់ ពីបណ្តាប្រទេសប្រជាធិបតេយ្យ។ ពិតប្រាកដណាស់ហើយថា វាគ្មានភាពស្របច្បាប់ខ្ពស់ជាង ភាពស្របច្បាប់ នៃរដ្ឋនីមួយៗ ស្របតាម កតិកាសញ្ញា នៅដំបន់ Westphalie[4] នៅប្រទេសអាល្លឺម៉ង់ ដែលគេទុកជាមូលដ្ឋាន នៃច្បាប់អន្តរជាតិ រហូតមកដល់សព្វថ្ងៃនេះ ដើម្បីរក្សាសន្តិភាពនៅលើពិភពលោក។ តែគោលការណ៍ នៃអធិបតេយ្យភាព វាមិនអាច ផ្តល់សិទ្ធិ ជាស្វ័យប្រវត្តិ ដល់របបដឹកនាំ នៃរដ្ឋនីមួយៗ ដែល អនុវត្តនយោបាយ ប្រឆាំងនឹងមនុស្សជាតិ ដែលមាន ច្បាប់សិទ្ធិមនុស្ស មានចារនៅក្នុងធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ សំរាប់ការពារ។ ដូច្នេះ ការវិវត្តបែបថយក្រោយ នៃលទ្ធិប្រជាធិបតេយ្យ វាគ្រាន់តែជារូបភាព នៃការឆ្លៀតដកខ្យល់កខ្វក់ នៃពួកមេដឹកនាំផ្តាច់ការ តាមរន្ធតូចៗខ្លះ ដែលលទ្ធិប្រជាធិបតេយ្យសេរី មិនទាន់បិទអស់។ តែលើក

[4] កតិកាសញ្ញា នៃ Westphalie (ឬ សន្តិភាព នៃ Westphalie) ដែលបានចុះហត្ថលេខានៅថ្ងៃទី២៤ តុលា ឆ្នាំ ១៦៤៨ បានបញ្ចប់ទំនាស់ពីរនៅអឺរ៉ុប ៖ សង្គ្រាម ៣០ឆ្នាំ រវាង សន្តចក្រភពរ៉ូម៉ាំង ជាមួយនឹង រដ្ឋអាល្លឺម៉ង់ប្រូតេស្តង់ទាំងឡាយដើបបះបោរ និង សង្គ្រាម ៨០ឆ្នាំង រវាងប្រទេសហូឡង់ ឬ សហខេត្ត ដើបប្រឆាំងនឹង រាជាណាចក្រអេស្ប៉ាញ។ កតិកាសញ្ញានេះ វាផ្តល់នូវតុល្យភាព នយោបាយ និង សាសនា នៅអឺរ៉ុប ព្រោះគេទទួលស្គាល់អធិបតេយ្យភាព នៃរដ្ឋនីមួយៗ ជាមូលដ្ឋាន ដែលត្រូវតែគោរពជាដាច់ខាត។

លែងតែមនុស្សទុច្ចរិត មនុស្សលោកនៅលើពិភពលោកសព្វថ្ងៃ មានជំនឿដាច់ខាតទៅលើតម្លៃ នៃលទ្ធិប្រជាធិបតេយ្យ ដែលជាតម្លៃស្ថាបនា នៃពិភពលោកប្រសើរ សម្រាប់មនុស្សជាតិ។ មុនពេល មានការយល់ដឹងពិតប្រាកដ នៃការគំរាមកំហែង និង ការបង្ហូរឈាម នៅក្នុងលោក « ក្រៅច្បាប់ និង នៅក្នុងការក្តាប់អំណាចផ្តាច់ការ នៃលទ្ធិកុម្មុយនិស្ត » មនុស្សលោកមិនដែលភ្លេចសោះឡើយ នៃសេរីភាព ជាធម្មជាតិរបស់ខ្លួន ហើយសេរីភាពនេះឯង គឺជាចំណុចចាប់ផ្តើម នៃការយល់ដឹងអំពីតម្លៃ នៃមនុស្សជាតិ ហើយខំស្វែងរកដោយខ្លួន នូវវិធីសាស្ត្ររដ្ឋាភិបាល ដែលឆ្លើយតបទៅនឹង សេចក្តីប្រាថ្នា នៃសេរីភាព។ វិធីសាស្ត្រនោះ គឺ លទ្ធិប្រជាធិបតេយ្យសេរីនេះឯង។ តែសព្វថ្ងៃ ពួកនយ:ជន ត្រូវបន្តធ្វើឱ្យលទ្ធិនេះ ក្លាយជាកម្លាំង នៃចក្ខុវិស័យ, សំណើរ និង មនោគតិ ដែលជាការចាំបាច់ សម្រាប់វឌ្ឍនភាពរបស់មនុស្សជាតិ ឥឡូវ និង អនាគត។ ត្រូវដឹងថាគ្មាននរណា អាចសម្លាប់ សេរីភាព បាននោះឡើយ៕